ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្តសៀមរាប

# វិទ្យាល័យអង្គរ

## រូបមន្តសង្ខេប

# រូបវិទ្យា

## ថ្នាក់ទី១២

សម្រាប់ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

បង្រៀនដោយៈ ដូ ចំណាន

# រូបមន្តសង្ខេប

## ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ជួ ចំណាន
Tel: 012 881 986

### ***មេរៀនទី១ ទ្រឹស្តីស៊ីនេទិចនៃឧស្ម័ន

**1). គោលទ្រឹស្តីស៊ីនេទិចនៃឧស្ម័ន:**

-ម៉ូលេគុលឧស្ម័នមានចលនាឥតឈប់ឈរ និងគ្មានសណ្តាប់ធ្នាប់។

-ទង្គិចរវាងម៉ូលេគុល និងធុងផ្ទុកវាជាទង្គិចខ្ទាត ។

-សន្មតនៅចន្លោះពេលទង្គិច ម៉ូលេគុលមានចលនាត្រង់ស្មើ ។

-តម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ម៉ូលេគុលអាស្រ័យនឹងសីតុណ្ហភាព។

-គេចាត់ទុកម៉ូលេគុលឧស្ម័ននីមួយៗ ជាចំនុចរូបធាតុ ។

**2). សីតុណ្ហភាពដាច់ខាត:** $T = t + 273$

**3). ចំនួនម៉ូលនៃឧស្ម័ន $(n)$:** $n = \frac{m}{M} = \frac{N}{N_A} = \frac{V}{V_{mol}}$

**4). សម្ពាធលើផ្ទៃខាង:** $P = \frac{F}{A}$ ★**កម្លាំងសរុប:** $F = N \times F_0$

**5). បម្រែបម្រួលបរិមាណចលនាក្នុង $\Delta t$ ស្មើអាំពុលស្យុង:** $F_0 \cdot \Delta t = \Delta P$

**6). ទំនាក់ទំនងសម្ពាធឧស្ម័ន និងតម្លៃមធ្យមនៃថាមពលស៊ីនេទិច:**

$$P = \frac{2}{3}\left(\frac{N}{V}\right)K_{av} = \frac{2}{3}\left(\frac{N}{V}\right)\times\frac{1}{2}m_0\left(v^2\right)_{av}$$

**7). សមីការឧស្ម័នបរិសុទ្ធ:**

$$PV = nRT = k_B NT = \frac{2}{3}NK_{av}$$

★**ថេរបុលស្មាន់:** $k_B = \frac{R}{N_A}$

★**ភាពដើម:** $P_1V_1 = nRT_1$ ①

★**ភាពស្រេច:** $P_2V_2 = nRT_2$ ②

**8). ថាមពលស៊ីនេទិចមធ្យមនៃម៉ូលេគុលឧស្ម័នទី១ៗ(1ម៉ូលេគុល):**

$$K_{av} = \frac{3}{2}k_B T = \frac{3PV}{2N} = \frac{1}{2}m_0\left(v^2\right)_{av}$$

**9). ថាមពលស៊ីនេទិចសរុបនៃឧស្ម័ន ($N$ ម៉ូលេគុល):**

$$K = NK_{av} = \frac{3}{2}nRT = \frac{3}{2}k_B NT = \frac{3}{2}PV$$

**10). ល្បឿនប្រសិទ្ធ=ឬសការេនៃការេល្បឿនមធ្យម** $\left(v_{rms} = \sqrt{(v^2)_{av}} = v_{av}\right)$:

$$v_{rms} = \sqrt{\frac{3k_B T}{m_0}} \Leftrightarrow T = \frac{m_0\left(v_{rms}\right)^2}{3k_B}$$

$$v_{rms} = \sqrt{\frac{3RT}{M}} \Leftrightarrow T = \frac{M\left(v_{rms}\right)^2}{3R}$$

✧ $N_A = 6.022 \cdot 10^{23}$ **ម៉ូលេគុល** $/ mol$

✧ $k_B = 1.38 \cdot 10^{-23} J/K$ **ជាថេរបុលស្មាន់**

✧ $R = 8.31 J/mol \cdot K$ **ជាថេរឧស្ម័នបរិសុទ្ធ**

✧ $V_{mol} = 22.4 \ell / mol$ **ជាមាឌនៅលក្ខខ័ណ្ឌធម្មតា**

$n(mol)$ ជាចំនួនម៉ូលនៃឧស្ម័ន

$N$ ជាចំនួនម៉ូលេគុលសរុបនៃឧស្ម័ន

$N_A$ (ម៉ូលេគុល $/ mol$): ជាចំនួនអាវ៉ូកាដ្រូ

$T(K)$ ជាសីតុណ្ហភាពដាច់ខាត

$t(°C)$ ជាសីតុណ្ហភាពសែលស្យុស

$\Delta P(kg \cdot m/s)$ ជាបរិមាណចលនា

★ទង្គិចស្អក់: $\Delta P = m_0 v$

★ទង្គិចខ្ទាត: $\Delta P = 2m_0 v$

$m(kg)$ ជាម៉ាសសរុបនៃឧស្ម័ន

$m_0(kg)$ ម៉ាសម៉ូលេគុលនី១ៗ

$M(kg/mol)$ ជាម៉ាសម៉ូលនៃឧស្ម័ន

$V(m^3)$ ជាមាឌរបស់ឧស្ម័ន ឬមាឌគូប

$P(Pa; N/m^2)$ ជាសម្ពាធនៃឧស្ម័ន

$\Delta t(s)$ ជាបម្រែបម្រួលរយៈពេល

$A(m^2)$ ជាក្រលាផ្ទៃខាងគូប(ផ្ទៃខាងធុង)

$F(N)$ ជាកម្លាំងសរុបលើផ្ទៃខាង

$F_0(N)$ ជាកម្លាំង១ម៉ូលេគុលឧស្ម័ន

$L(m)$ ជាប្រវែងទ្រនុងខាងគូប(ជ្រុង)

$K_{av}(J)$ ជាតម្លៃមធ្យមនៃថាមពលស៊ីនេទិច

$K(J)$ ជាថាមពលស៊ីនេទិចសរុប

$\rho(kg/m^3)$ ជាម៉ាសមាឌនៃឧស្ម័ន

$v_{rms}(m/s)$ ជាល្បឿនប្រសិទ្ធនៃម៉ូលេគុល ឬ ល្បឿនឫសការេនៃការេល្បឿនមធ្យម

$v(m/s)$ ជាល្បឿននៃឧស្ម័ន

★**ខ្នាតសម្ពាធ:** $1atm = 76cmHg = 10^5 Pa$

★**ខ្នាតមាឌ:** $1\ell = 1dm^3 = 10^{-3}m^3$

①**ម៉ាសមាឌនៃឧស្ម័ន:** $\rho = \frac{m}{V}$ ②**ម៉ាសសរុបនៃឧស្ម័ន:** $m = N \cdot m_0$ ③**ទំនាក់ទំនងរវាង** $m_0$ & $M$: $M = m_0 \times N_A$

④**មាឌរបស់គូប:** $V = A \cdot L = L^3$ ⑤**មាឌរបស់ស៊ីឡាំង:** $V = A \cdot h$ ⑥**មាឌរបស់ស្វ៊ែ (បាល់ឡុង):** $V = \frac{4}{3}\pi R^3$

## ***មេរៀនទី២ ច្បាប់ទីមួយនៃទែម៉ូឌីណាមិច

① ច្បាប់ទីមួយទែម៉ូឌីណាមិចសិក្សាអំពី: បម្លែងថាមពលកម្តៅ ទៅជាកម្មន្ត ឬ ថាមពលបែបផ្សេងៗទៀត ។

② ពោលច្បាប់ទីមួយនៃទែម៉ូឌីណាមិច: ក្នុងបំលែងទែម៉ូឌីណាមិច កម្តៅស្រូបដោយប្រព័ន្ធ $(Q)$ ស្មើនឹងផលបូកកម្មន្តដែលបង្កើតឡើងដោយប្រព័ន្ធ $(W)$ និងបម្រែបម្រួលថាមពលក្នុងនៃប្រព័ន្ធ $(\Delta U)$ ។ គេបាន: $Q = \Delta U + W$

③ បំលែងទែម៉ូឌីណាមិច: ប្រព័ន្ធមួយទទួលបំលែងទែម៉ូឌីណាមិច កាលណាវាផ្លាស់ប្តូរភាពដោយប្តូរតែកម្មន្ត និងកម្តៅជាមួយមជ្ឈដ្ឋានក្រៅប៉ុណ្ណោះ ។

④ ប្រព័ន្ធ: គឺជាវត្ថុ ឬសំណុំវត្ថុដែលគេលើកយកមកសិក្សាធៀបនឹងវត្ថុដទៃទៀត។

⑤ ប្រព័ន្ធទែម៉ូឌីណាមិច: គឺជាប្រព័ន្ធដែលទទួលបំលែងទែម៉ូឌីណាមិចអាចចេញពី ភាពដើមមួយទៅ ភាពស្រេចមួយ តាមដំណើរប្រព្រឹត្តខុសៗគ្នាបាន។

⑥ ភាពនៃប្រព័ន្ធ: គឺជាសំណុំលេខវាស់ទំហំរូបវិទ្យានៅខណៈណាមួយ ។

⑦ បំលែងចំហ: គឺជាបំលែងដែលប្រព័ន្ធមានភាពដើម និងភាពស្រេចខុសគ្នា។

⑧ បំលែងបិទ: គឺជាបំលែងដែល ប្រព័ន្ធមានភាពដើម និងភាពស្រេចដូចគ្នា។

### ***របៀបរក កម្មន្តបំពេញដោយប្រព័ន្ធ:

1). ករណីមាឌថេរ: លំនាំអ៊ីសូករ(V=ថេរ) ⇒ $W = 0J$




2). ករណីសម្ពាធថេរ: លំនាំអ៊ីសូបា(P=ថេរ)

$W = P\cdot\Delta V = P(V_2 - V_1)$ $(\Delta V = A\cdot\Delta x)$




3). ❶ ករណីសម្ពាធប្រែប្រួលស្មើ:

$$W = P_{av}\Delta V = \frac{P_1 + P_2}{2}\Delta V$$

❷ ករណីសម្ពាធប្រែប្រួល:

$$W = P_1\Delta V + \frac{1}{2}(P_2 - P_1)\Delta V$$




4). ករណីសីតុណ្ហភាពថេរ: លំនាំអ៊ីសូទែម(T=ថេរ)

$$W = nRT\cdot\ln\left(\frac{V_2}{V_1}\right) = PV\cdot\ln\left(\frac{V_2}{V_1}\right) = k_B NT\cdot\ln\left(\frac{V_2}{V_1}\right)$$




5). ថាមពលក្នុងនៃឧស្ម័នបរិសុទ្ធ គឺជាថាមពលស៊ីនេទិចសរុបនៃម៉ូលេគុលនៃឧស្ម័ន:

$$U = K = \frac{3}{2}nRT = \frac{3}{2}k_B NT = \frac{3}{2}PV$$

6). បម្រែបម្រួលថាមពលក្នុងរបស់ប្រព័ន្ធ:

$$\Delta U = U_2 - U_1 = \frac{3}{2}P_2V_2 - \frac{3}{2}P_1V_1 = \frac{3}{2}nRT_2 - \frac{3}{2}nRT_1 = \frac{3}{2}nR\Delta T$$

$(\Delta T = T_2 - T_1 \text{ , } \Delta U = U_2 - U_1)$

7). ច្បាប់ទីមួយទែម៉ូឌីណាមិច: $Q = \Delta U + W \Leftrightarrow \Delta U = Q - W$

---

$W(J)$ ជាកម្មន្តបំពេញដោយឧស្ម័ន

$V_1(m^3)$ ជាមាឌនៅទីតាំងដើម

$V_2(m^3)$ ជាមាឌនៅទីតាំងស្រេច

$\Delta V = V_2 - V_1$ ជាបម្រែបម្រួលមាឌ

$P(Pa)$ ជាសម្ពាធនៃឧស្ម័ន

$P_1(Pa)$ ជាសម្ពាធទីតាំងដើម

$P_2(Pa)$ ជាសម្ពាធទីតាំងស្រេច

$P_{av}(Pa)$ ជាតម្លៃមធ្យមនៃសម្ពាធ

$Q(J)$ ជាបរិមាណកម្តៅស្រូប ឬបញ្ចេញ

$W(J)$ ជាកម្មន្តបំពេញ(ដោយប្រព័ន្ធ)

$U(J)$ ជាថាមពលក្នុងនៃប្រព័ន្ធ

$\Delta U(J)$ ជាបម្រែបម្រួលថាមពលក្នុង

*មាឌស៊ីឡាំង=ក្រឡាផ្ទៃបាត x កម្ពស់

### ***សិក្សាសញ្ញាសម្គាល់៖

❶ $Q > 0$: ប្រព័ន្ធស្រូប-ទទួលកម្តៅ

❷ $Q < 0$: ប្រព័ន្ធបញ្ចេញ-បំភាយកម្តៅ

❸ $W > 0$: ប្រព័ន្ធបំពេញ-បញ្ចេញ-ធ្វើកម្មន្ត

❹ $W < 0$: ប្រព័ន្ធទទួល -រងកម្មន្ត

❺ $\Delta U > 0$: ថាមពលក្នុងនៃប្រព័ន្ធកើន

❻ $\Delta U < 0$: ថាមពលក្នុងនៃប្រព័ន្ធថយចុះ

❼ $Q = 0$: លំនាំអាដ្យាបាទិច

❽ $W = 0$: លំនាំអ៊ីសូករ

❾ $\Delta U = 0$: លំនាំអ៊ីសូទែម ឬបំលែងបិទ:

▪ $T$ ថេរ $\Delta T = 0 \Leftrightarrow \Delta U = 0 \Rightarrow Q = W$

▪ $V$ ថេរ $\Delta V = 0 \Leftrightarrow W = 0 \Rightarrow \Delta U = Q$

# រូបមន្តសង្ខេប

## ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ឌូ ចំណាន
Tel: 012 881 986

## ***មេរៀនទី៣ ម៉ាស៊ីន

**I. លំនាំអាដ្យាបាទិច:** ជាលំនាំមួយដែលថាមពលកម្ដៅមិនប្ដូរជាមួយមជ្ឈដ្ឋានក្រៅ $(Q=0)$ ។ គេបាន: $W=-\Delta U$ ។

**II. ស៊ិចកាកណូ:** ជាលំនាំវេវស៊ីបនៃម៉ាស៊ីនប្រើកម្ដៅមួយដំណើរការនៅចន្លោះប្រភពកម្ដៅពីរមានសីតុណ្ហភាពខុសគ្នាដែលផ្ដួចផ្ដើមដោយលោក **សាឌីកាកណូ** ។ ដំណាក់កាលទាំង៤ស៊ិចកាកណូគឺ:




- ដំណាក់កាលទី១: ឧស្ម័នស្រូបកម្ដៅ $Q_h$ ពីធុងក្ដៅ $T_h$ រីកមាឌតាមលំនាំអ៊ីសូទែម $(A\rightarrow B)$ ។
- ដំណាក់កាលទី២: ឧស្ម័នបន្តរីកមាឌតាមលំនាំអាដ្យាបាទិច $(B\rightarrow C)$ ។
- ដំណាក់កាលទី៣: ឧស្ម័នបញ្ចេញកម្ដៅ $Q_C$ ទៅធុងត្រជាក់ $T_C$ រួមមាឌតាមលំនាំអ៊ីសូទែម $(C\rightarrow D)$ ។
- ដំណាក់កាលទី៤: ឧស្ម័នត្រូវបានបណ្ណែនតាមលំនាំអាដ្យាបាទិចរហូតដល់ស្ថានភាពដើមវិញ $(D\rightarrow A)$ ។

**III. ទ្រឹស្ដីបទកាកណូ និងទិន្នផលកម្ដៅអតិបរមា( ម៉ាស៊ីនកាកណូ/ម៉ាស៊ីនអ៊ីដេអាល់/ម៉ាស៊ីនប្រើចំហាយទឹក ):**

- ចំពោះម៉ូទ័រប្រើកម្ដៅដែលទាក់ទងនឹងប្រភពកម្ដៅពីរ ទិន្នផលកម្ដៅមានតម្លៃអតិបរមាកាលណាភ្នាក់ងារកម្ដៅ វិវត្តតាមស៊ិចរេវ៉ស៊ីប ។
- ក្នុងករណីនេះទិន្នផលកម្ដៅអតិបរមា មិនអាស្រ័យនឹងប្រភេទនៃភ្នាក់ងារកម្ដៅ និងរបៀបវិវត្តនៃស៊ិចរេវ៉ស៊ីបទេ។
- ទិន្នផលនោះអាស្រ័យតែនឹងសីតុណ្ហភាពដាច់ខាត $T_h$ នៃប្រភពក្ដៅ និង $T_C$ នៃប្រភពត្រជាក់ ។

| | |
|---|---|
| 1). តុល្យការថាមពល: | $Q_h=Q_c+W$ |
| 2). ទិន្នផលម៉ាស៊ីន: | $e=\dfrac{W}{Q_h}=1-\dfrac{Q_C}{Q_h}$ |
| 3). ផលធៀបម៉ាស៊ីនអ៊ីដេអាល់: | $\dfrac{Q_C}{Q_h}=\dfrac{T_C}{T_h}$ |
| 4). ទិន្នផលម៉ាស៊ីនអ៊ីដេអាល់: | $e=1-\dfrac{T_C}{T_h}=1-\dfrac{Q_C}{Q_h}$ |
| 5). អានុភាពមធ្យមនៃម៉ាស៊ីន: | $P=\dfrac{W}{t}$ |







**IV. ម៉ាស៊ីនសាំង / ម៉ាស៊ីនម៉ាស៊ូត / ម៉ាស៊ីនម៉ូទ័របន្ទុះបួនចង្វាក់:**

- វគ្គទី១(សម្រូប): ពីស្តុងធ្លាក់ចុះក្រោម ស្រូបល្បាយសាំង-ខ្យល់ក្នុងស៊ីឡាំង ។
- វគ្គទី២(បណ្ណែន): ពីស្តុងផ្លាស់ទីឡើងលើបណ្ណែនល្បាយសាំង-ខ្យល់ក្នុងស៊ីឡាំង ។
- វគ្គទី៣(បន្ទុះនិងបន្ធូរ): ប៊ូស៊ីបំព្រាយផ្កាភ្លើងឆេះល្បាយសាំង-ខ្យល់ ។
- វគ្គទី៤(បញ្ចេញ): ពីស្តុងផ្លាស់ទីឡើងលើ បញ្ចេញកាកសំណល់ចំហេះទៅក្រៅ ។




| | |
|---|---|
| 1). ថាមពលកម្ដៅផ្ដល់ចំហេះ: | $Q_h=mq$ |
| 2). ថាមពលកម្ដៅស្រូប: | $Q_h=Q_C+W_M$ |
| 3). ទិន្នផលម៉ាស៊ីន ឬម៉ូទ័រ: | $e_C=\dfrac{W_M}{Q_h}$ |
| 4). ទិន្នផលគ្រឿងបញ្ជូន ឬមេកានិច: | $e_M=\dfrac{W_U}{W_M}$ |
| 5). ទិន្នផលបានការនៃម៉ាស៊ីន ឬសរុប: | $e=\dfrac{W_U}{Q_h}=e_C\times e_M$ |

★**សំគាល់:** ម៉ាស៊ីនប្រើសាំងមានទិន្នផលប្រហែល 30% រីឯម៉ាស៊ីនម៉ាស៊ូតមានទិន្នផលរហូតដល់ 39% ។

- $e(\%)$ ទិន្នផលកម្ដៅនៃម៉ាស៊ីនកាកណូ
- $Q_h(J)$ បរិមាណកម្ដៅស្រូបនៅធុងក្ដៅ
- $Q_c(J)$ បរិមាណកម្ដៅបំភាយទៅធុងត្រជាក់
- $W(J)$ កម្មន្តដែលឧស្ម័នធ្វើ
- $T_h(K)$ សីតុណ្ហភាពខ្ពស់នៅធុងក្ដៅ
- $T_C(K)$ សីតុណ្ហភាពទាបនៅធុងត្រជាក់
- $P(W)$ អានុភាពមធ្យមនៃម៉ាស៊ីន
- $t(s)$ រយៈពេលដំណើរការ
- $e_C(\%)$ ទិន្នផលម៉ាស៊ីន ឬម៉ូទ័រ
- $e_M(\%)$ ទិន្នផលគ្រឿងបញ្ជូន ឬមេកានិច
- $e(\%)$ ទិន្នផលបានការនៃម៉ាស៊ីន ឬសរុប
- $Q_h(J)$ បរិមាណកម្ដៅស្រូប ឬទទួលពីម៉ាស៊ីន
- $Q_c(J)$ បរិមាណកម្ដៅបំភាយទៅមជ្ឈដ្ឋានក្រៅ
- $Q_C'(J)$ បរិមាណកម្ដៅបាត់បង់ដោយកកិត
- $W_M(J)$ កម្មន្តមេកានិច ឬថាមពលមេកានិច
- $W_U(J)$ កម្មន្តបានការ ឬទទួលដោយភ្លៅម៉ូទ័រ
- $m(kg)$ ម៉ាសល្បាយសាំង
- $q(J/kg)$ អំណាចកម្ដៅ

# រូបមន្តសង្ខេប

## ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

ជួ ចំណាន
Tel: 012 881 986

## ***មេរៀនទី៤ គោលការណ៍តម្រួតនៃរលក និងរលកជញ្ជ្រំ

**I. រលក:** គឺជាការបញ្ជូនថាមពលពីចំណុចមួយទៅចំណុចផ្សេងទៀតតាមរយៈមជ្ឈដ្ឋានណាមួយ ។

1). ជំហានរលក: $\lambda = T \cdot v = \frac{v}{f}$

2). ចំនួនរលក: $k = \frac{2\pi}{\lambda} = \frac{\omega}{v}$

3). ខួបនៃរលក: $T = \frac{1}{f} = \frac{2\pi}{\omega} = \frac{\lambda}{v}$

4). ប្រេកង់នៃរលក: $f = \frac{1}{T} = \frac{\omega}{2\pi} = \frac{v}{\lambda}$

5). ពុលសាស្យុង: $\omega = \frac{2\pi}{T} = 2\pi f = v \cdot k$

6). ល្បឿនដំណាលនៃរលក: $v = \frac{d}{t} = \frac{\lambda}{T} = \lambda f$

$\lambda(m)$: ជំហានរលក
$v(m/s)$: ល្បឿនដំណាលរលក
$T(s)$: ខួបនៃរលក
$f(Hz)$; (ជុំ/s): ប្រេកង់រលក
$\omega(rad/s)$: ពុលសាស្យុងរលក
$k(rad/m)$: ចំនួនរលក
$d(m)$: ចម្ងាយចររលកដាល
$t(s)$: រយៈពេលរលកដាល
$y(m)$: អេឡុងកាស្យុង
$y_1(m)$: អេឡុងកាស្យុងនៃរលកទី១
$y_2(m)$: អេឡុងកាស្យុងនៃរលកទី២
$a(m)$: អំភ្លីទុតរលក
$a_1(m)$: អំភ្លីទុតនៃរលកទី១
$a_2(m)$: អំភ្លីទុតនៃរលកទី២
$(\omega t + \varphi)(rad)$: ផាសខណៈ $t$
$\varphi(rad)$: ផាសដើម
$\varphi_1(rad)$: ផាសដើមនៃរលកទី១
$\varphi_2(rad)$: ផាសដើមនៃរលកទី២
$\Delta\varphi(rad)$: គម្លាតផាស ឬ ផលសងផាស

**II. រលកតម្រួត:** ជាផលបូកវ៉ិចទ័រ នៃបណ្តាចំណុចបម្លាស់ទីរលកទោលទាំងនោះ ។

✦សមីការរលកទី១: $y_1 = a_1 \sin(\omega t + \varphi_1)$ ✦សមីការរលកទី២: $y_2 = a_2 \sin(\omega t + \varphi_2)$

1). សមីការនៃរលកតម្រួត: $y = y_1 + y_2 = a\sin(\omega t + \varphi)$

2). អំភ្លីទុតនៃរលកតម្រួត: $a = \sqrt{a_1^2 + a_2^2 + 2a_1 a_2 \cos(\varphi_2 - \varphi_1)}$

3). ផាសដើមនៃរលកតម្រួត: $\tan\varphi = \frac{a_1 \sin\varphi_1 + a_2 \sin\varphi_2}{a_1 \cos\varphi_1 + a_2 \cos\varphi_2}$

4). គម្លាតផាសរវាងរលកទាំងពីរ: $\Delta\varphi = \varphi_2 - \varphi_1 = \frac{2\pi d}{\lambda}$

★ករណីអំភ្លីទុត: $a_1 = a_2$: តាម $\sin A + \sin B = 2\sin\left(\frac{A+B}{2}\right)\cos\left(\frac{A-B}{2}\right)$

★ករណី $n$ សមីការរលក:

1). សមីការនៃរលកតម្រួត: $y = y_1 + y_2 + \ldots\ldots + y_n = a\sin(\omega t + \varphi)$

✦លើអ័ក្ស $(ox)$: $a_x = a_1 \cos\varphi_1 + a_2 \cos\varphi_2 + \ldots\ldots + a_n \cos\varphi_n$

✦លើអ័ក្ស $(oy)$: $a_y = a_1 \sin\varphi_1 + a_2 \sin\varphi_2 + \ldots\ldots + a_n \sin\varphi_n$

2). អំភ្លីទុតរលកតម្រួត: $a = \sqrt{a_x^2 + a_y^2}$ 3). ផាសដើមរលកតម្រួត: $\tan\varphi = \frac{a_y}{a_x}$

**III. សមីការចលនានៃចំណុច $M$ នៅចម្ងាយ $x$ ពីប្រភពរលក $O$**




★ សមីការរលកដាលត្រង់ប្រភព $O$: $y_0 = a\sin\omega t = a\sin\left(\frac{2\pi}{T}t\right)$

★ សមីការរលកដាលត្រង់ចំណុច $M$: $y_M = a\sin\frac{2\pi}{T}\left(t - \frac{x}{v}\right) = a\sin 2\pi\left(\frac{t}{T} - \frac{x}{\lambda}\right) = a\sin(\omega t - kx)$

**IV. រលកជញ្ជ្រំ:** គឺជារលកស៊ីនុយសូអ៊ីតពីរ ដែលមានអំភ្លីទុត និងជំហានរលកដូចគ្នាផ្លាស់ទីតាមទិសដៅផ្ទុយគ្នា ។

✦ រលកទី១ផ្លាស់ទីទៅស្តាំ: $y_1 = a\sin(kx - \omega t)$ ✦រលកទី២ផ្លាស់ទីទៅឆ្វេង: $y_2 = a\sin(kx + \omega t)$

★ តាមគោលការណ៍រលកតម្រួត: $y = y_1 + y_2 = a\sin(kx - \omega t) + a\sin(kx + \omega t)$

1). សមីការរលកជញ្ជ្រំ: $y = 2a\sin(kx)\cos(\omega t)$ 2). អំភ្លីទុតរលកជញ្ជ្រំ: $A = 2a\sin(kx)$

3). ទីតាំងថ្នាំងនៃរលកជញ្ជ្រំ: $x = n\frac{\lambda}{2}$ $(n = 0,1,2,3,\ldots)$

4). ទីតាំងពោះនៃរលកជញ្ជ្រំ: $x = n\frac{\lambda}{4}$ $(n = 1,3,5,7,\ldots)$

5). ចំនួនក្រយ៉ុង: $n = \frac{2L}{\lambda}$ $L(m)$: ជាប្រវែងខ្សែ

★**រេសូណង់:** គឺជាបាតុភូតមួយកើតឡើងកាលណា ប្រេកង់នៃកម្លាំងក្រៅមានតម្លៃស្មើ ឬជិតស្មើនឹងប្រេកង់ផ្ទាល់នៃអង្គធាតុហើយធ្វើឱ្យអង្គធាតុយោលកាន់តែខ្លាំង។ រេសូណង់មានពីរគឺ:រេសូណង់ស្ទក់ & រេសូណង់ស្រួច។

## ***មេរៀនទី៦ ដែន និងកម្លាំងម៉ាញេទិច

**1). មេដែក:** គឺជាអង្គធាតុដែលអាចឆក់ទាញដែក និងកំទេចដែក នៅតំបន់ចុងទាំងពីររបស់វាគេហៅថា **ប៉ូលនៃមេដែក** ។

★ មេដែកមានពីរគឺ: មេដែកធម្មជាតិ និងមេដែកសិប្បនិម្មិត ។

- មេដែកធម្មជាតិ ជាមេដែកដែលមានស្រាប់ក្នុងធម្មជាតិ ។ ឧទាហរណ៍: ដែកអុកស៊ីតម៉ាញេទិច $(Fe_3O_4)$ ។
- មេដែកសិប្បនិម្មិត ជាមេដែកដែលបង្កើតឡើងដោយមនុស្ស ។ ឧទាហរណ៍: ម្ជុលមេដែក របារមេដែក និងមេដែករាង$U$ ។

★ មេដែកមានប៉ូលពីរគឺ: ប៉ូលជើង$(N)$ និងប៉ូលត្បូង$(S)$ ។

**2). ដែនម៉ាញេទិច:** គឺជាលំហដែលនៅព័ទ្ធជុំវិញមេដែក ហើយអាចបង្កើតនូវកម្លាំងម៉ាញេទិចបាន។ ដែនម៉ាញេទិចតាងដោយវ៉ិចទ័រ $\vec{B}$ ហៅថាវ៉ិចទ័រ**ដែនម៉ាញេទិច** ឬវ៉ិចទ័រ**អាំងឌុចស្យុង** មានខ្នាតគិតជា **តេស្លា**$(T)$ ។

★ ដែនម៉ាញេទិចមានទិសដៅ ចូលតាមប៉ូលត្បូង$(S)$និងចេញតាមប៉ូលជើង$(N)$ ។

**3). ដែនម៉ាញេទិចឯកសណ្ឋាន:** ជាដែនម៉ាញេទិចដែលមានខ្សែដែនជាបន្ទាត់ស្របៗគ្នាមានទិស ទិសដៅដូចគ្នា អាំងតង់ស៊ីតេស្មើគ្នាជានិច្ច។ ដែនម៉ាញេទិចឯកសណ្ឋានកើតមាន៖ - នៅចន្លោះប៉ូលទាំងពីរនៃមេដែករាង$U$ - នៅខាងក្នុងសូលេណូអ៊ីត - នៅចន្លោះបូប៊ីន ហ៊ីម-ហុល។

**4). ដែនម៉ាញេទិចផែនដី:** ជុំវិញផែនដីមានដែនម៉ាញេទិចមួយដែរ ហេតុនេះហើយទើបត្រីវិស័យដែលជាម្ជុលមេដែកចង្អុលទៅទិសខាងជើងរហូត ។ ដែលមានតម្លៃ: $B_0 = 2\times10^{-5}T$

**5). ដែនម៉ាញេទិចនៃចរន្តត្រង់:** តាមវិធានដៃស្តាំ (ដៃស្តាំក្តោបយ៉ាងណាឲ្យមេដៃកន្ទ្រកចង្អុលទិសដៅចរន្តហើយម្រាមទាំង៤ចង្អុលទិសដៅខ្សែដែនម៉ាញេទិច)។

★ក្នុងសុញ្ញាកាស ឬខ្យល់: $B = \dfrac{\mu_0 I}{2\pi d}$ ★ក្នុងមជ្ឈដ្ឋានណា១$(\mu_r)$: $B = \dfrac{\mu_0 \mu_r I}{2\pi d}$

**6). ដែនម៉ាញេទិចបង្កើតដោយចរន្តវង់:** តាមវិធានដៃស្តាំ (ដៃស្តាំក្តោបម្រាមទាំង៤តាមទិសដៅចរន្ត រួចកន្ទ្រកមេដៃចង្អុលទិសដៅដែនម៉ាញេទិច) ។

★ចំពោះស្ពៀ១ស្ពៀ: $B = \dfrac{\mu_0 I}{2R}$ ★បូប៊ីនសំប៉ែតមាន $N$ ស្ពៀ: $B = \dfrac{\mu_0 N I}{2R}$

**7). ដែនម៉ាញេទិចនៃសូលេណូអ៊ីត:** សូលេណូអ៊ីតជាបូប៊ីនដែលមានប្រវែងវែងជាងកាំ៥ដង$(\ell \geq 5R)$។

★លក្ខណៈសម្គាល់វ៉ិចទ័រដែនម៉ាញេទិចក្នុងសូលេណូអ៊ីតមាន៖

-ចំណុចចាប់: ត្រង់ផ្ចិតនៃសូលេណូអ៊ីត -ទិស : ស្របនឹងអ័ក្សសូលេណូអ៊ីត

-ទិសដៅ: តាមវិធានដៃស្តាំ(ដៃស្តាំក្តោបម្រាមទាំង៤តាមទិសដៅចរន្តរួចកន្ទ្រកមេដៃចង្អុលទិសដៅដែនម៉ាញេទិច)។

-អាំងតង់ស៊ីតេដែនម៉ាញេទិចនៃសូលេណូអ៊ីត: $B = \mu_0 n I = \dfrac{\mu_0 N I}{\ell}$ ដែល $n = \dfrac{N}{\ell}$

**8). ករណីរុំមួយជាន់ ឬមួយស្រទាប់៖**

❶ ករណីមិនគិតកម្រាស់$(e)$: $N = \dfrac{\ell}{d}$ ❷ ករណីគិតពីកម្រាស់$(e)$: $N = \dfrac{\ell}{d+2e}$

**9). ករណីរុំច្រើនជាន់($x$ ជាន់ ឬស្រទាប់)៖**

❶ បើមិនគិតកម្រាស់$(e)$: $N = \dfrac{x\cdot\ell}{d}$ ❷ បើគិតពីកម្រាស់$(e)$: $N = \dfrac{x\cdot\ell}{d+2e}$

**10). រកចំនួនស្ពៀ $N$ (តាមប្រវែងខ្សែចម្លង $\ell'$)៖** $\ell' = \pi D N \Rightarrow N = \dfrac{\ell'}{\pi D}$

**11). រេស៊ីស្តង់ខ្សែនៃសូលេណូអ៊ីត:** $R = \rho\dfrac{\ell'}{A'}$ ផ្ទៃមុខកាត់ខ្សែ: $A' = \pi\dfrac{d^2}{4}$

- $B_0(T)$ : ដែនម៉ាញេទិចផែនដី
- $B(T)$ : ដែនម៉ាញេទិចត្រង់M
- $I(A)$ : ចរន្តឆ្លងកាត់ខ្សែចម្លង
- $d(m)$ : ចម្ងាយពីខ្សែទៅចំណុចM
- $\mu_0 = 4\pi\times10^{-7}\ Tm/A$ : ជំរាបម៉ាញេទិច
- $\mu_r$ : ជំរាបម៉ាញេទិចធៀបនៃមជ្ឈដ្ឋាន
- $\mu$ : ជំរាបម៉ាញេទិចនៃមជ្ឈដ្ឋាន ដែល $\mu = \mu_0\times\mu_r$
- $R(m)$ : កាំមធ្យមបូប៊ីនសំប៉ែត
- $N$ : ចំនួនស្ពៀសរុប
- $\ell$ : ប្រវែងសូលេណូអ៊ីត $(m)$
- $A$ : ផ្ទៃមុខកាត់សូលេណូអ៊ីត $(m^2)$
- $D$ : អង្កត់ផ្ចិតសូលេណូអ៊ីត $(m)$
- $R$ : កាំសូលេណូអ៊ីត $(m)$
- $\ell'$ : ប្រវែងខ្សែចម្លង $(m)$
- $A'$ : ផ្ទៃមុខកាត់ខ្សែចម្លង $(m^2)$
- $d$ : អង្កត់ផ្ចិតខ្សែចម្លង $(m)$
- $x$ : ចំនួនស្រទាប់ ឬចំនួនជាន់
- $n$ : ចំនួនស្ពៀក្នុង 1m
- $e$ : កម្រាស់អ៊ីសូឡង់ $(m)$
- $R(\Omega)$ : រេស៊ីស្តង់នៃខ្សែ
- $\rho(\Omega m)$ : រេស៊ីស្ទីវីតេ (ប្រភេទខ្សែចម្លង)

**12). អំពើដែនម៉ាញេទិចលើរបារខ្សែចម្លង:** តាមវិធានដៃស្តាំ(លាតម្រាមទាំង៤តាមទិសដៅចរន្ត ហើយក្តោបម្រាមទាំង៤តាមវ៉ិចទ័រដែនម៉ាញេទិច $\vec{B}$ បន្ទាប់មកកន្ទេកមេដៃតាមទិសដៅកម្លាំងម៉ាញេទិច)។ **កម្លាំងអេឡិចត្រូម៉ាញេទិច:** $F = BI\ell \cdot \sin\theta$ ដែល: $\theta = (\vec{B};I)$

**13). កម្លាំងម៉ាញេទិចមានអំពើលើខ្សែទាំងពីរ:** $F = F_{12} = F_{21} = \dfrac{\mu_0 I_1 I_2 \ell}{2\pi a}$

-បើចរន្តមានទិសដៅដូចគ្នា នោះខ្សែចម្លងទាញគ្នាចូល

-បើចរន្តមានទិសដៅផ្ទុយគ្នា នោះខ្សែចម្លងច្រានគ្នាចេញ

**14). កម្លាំងម៉ាញេទិច: ច្បាប់ឡូរិន:** ពេលផង់ផ្ទុកបន្ទុកអគ្គិសនី $q$ ធ្វើចលនាចូលក្នុងដែនម៉ាញេទិចឯកសណ្ឋាន $\vec{B}$ ដោយល្បឿនដើម $\vec{v}_0$ នោះផង់រងនូវកម្លាំងម៉ាញេទិច $\vec{F}_m$ ៖ $F_m = |q| v_0 B \cdot \sin\alpha$ ដែល: $\alpha = (\vec{v}_0, \vec{B})$

★ បើ $\vec{v}_0 \perp \vec{B}$ យើងបាន: $F_m = |q| v_0 B$ ផង់មានគន្លងជារង្វង់ ។

★ បើ $\vec{v}_0 \uparrow\uparrow \vec{B}$ ឬ $\vec{v}_0 \uparrow\downarrow \vec{B}$ យើងបាន: $F_m = 0$ ផង់រក្សាគន្លងដើម ។

★ បើ $\alpha = (\vec{v}_0, \vec{B})$ យើងបាន: $F_m = |q| v_0 B \sin\alpha$ ផង់មានគន្លងជាស្ពៀរ៉ាល់ ឬអេលីស។



**15). លំងាកនៃផង់ផ្ទុកអគ្គិសនីដោយដែនម៉ាញេទិចឯកសណ្ឋាន:**

★ផង់ផ្ទុកអគ្គិសនី $q > 0$ ធ្វើចលនាចូលទៅក្នុងដែនម៉ាញេទិចឯកសណ្ឋាន $\vec{B}$ នៅត្រង់ចំណុច $O$ ដោយល្បឿន $\vec{v}_0$ កែងទៅនឹង $\vec{B}$ ដូចបង្ហាញលើរូប។ ផង់ផ្លាស់ទីដោយចលនារង្វង់ស្មើហើយ ផង់ផ្លាស់ទីវារង កម្លាំងម៉ាញេទិច $\vec{F}_m$ ដែលមាននាទីជា កម្លាំងចូលផ្ចិត ។

★ តាមច្បាប់ឡូរិន: $F_m = |q| v_0 B$ ❶ $(\vec{v}_0 \perp \vec{B})$

★ តាមកម្លាំងចូលផ្ចិត: $F_m = m \cdot a = m\dfrac{v_0^2}{R}$ ❷

★ តាម ❶ និង ❷ $\Rightarrow |q| v_0 B = m\dfrac{v_0^2}{R}$

**16). កាំរង្វង់:** $R = \dfrac{m v_0}{|q| B}$

**17). ល្បឿនមុំ:** $\omega = \dfrac{v_0}{R} = \dfrac{|q| B}{m}$

**18). ខួបរង្វិល:** $T = \dfrac{2\pi}{\omega} = \dfrac{2\pi R}{v_0}$




$F_m(N)$ : កម្លាំងម៉ាញេទិច
$B(T)$ : ដែនម៉ាញេទិច
$v_0(m/s)$ : ល្បឿនផង់
$R(m)$ : កាំនៃគន្លងរង្វង់
$m(kg)$ : ម៉ាសផង់
$q(C)$ : បន្ទុកអគ្គិសនីផង់
$T(s)$ : ខួបចលនាផង់
$\omega(rd/s)$ : ល្បឿនមុំ
$f(Hz)$; (ជុំ/s): ប្រេកង់

**19). លំងាក និងវេវ្លិចស្យុងម៉ាញេទិច:**

★ ពេលផង់ផ្លាស់ទីចូលដែនម៉ាញេទិចដោយល្បឿន $\vec{v}_0$ ត្រង់ចំណុច $O$ ហើយចេញពីដែននេះវិញត្រង់ $A$ ដោយល្បឿន $\vec{v}_A$ រួចបន្តទៅប៉ះអេក្រង់ត្រង់ចំណុច $P$ ។ មុំដែលផ្គុំរវាងវ៉ិចទ័រល្បឿន $\vec{v}_0$ និង $\vec{v}_A$ ហៅថា **លំងាកម៉ាញេទិច** ។

**ដូច្នេះ មុំលំងាកម៉ាញេទិច:** $\alpha = \dfrac{\ell}{R} = \dfrac{|q| B\ell}{m v_0}$ ដែល $\alpha$ គិតជារ៉ាដ្យង់ $(rad)$

★ បើសិនជាពុំមានដែនម៉ាញេទិចទេ ផង់ទៅដល់អេក្រង់ត្រង់ចំណុច $O'$ ប៉ុន្តែបើមានដែនម៉ាញេទិចវិញ ផង់នឹងទៅដល់អេក្រង់ត្រង់ $P$ ។ ចម្ងាយ $O'P = Z$ ហៅថា **វេវ្លិចស្យុងម៉ាញេទិច** ។ **ដូច្នេះ វេវ្លិចស្យុងម៉ាញេទិច:** $Z = D \cdot \alpha = \dfrac{|q| DB\ell}{m v_0}$

**20). ស្ប៉ិចត្រូម:** ជាឧបករណ៍ប្រើសម្រាប់ញែកផង់ផ្ទុកអគ្គិសនីដែលមានបន្ទុកក្នុងមួយខ្នាតម៉ាស $\left(\dfrac{|q|}{m}\right)$ ខុសៗគ្នា ។

★ **ពេលចេញពីដែនអគ្គិសនី:** $\Delta K = W \Leftrightarrow \dfrac{1}{2} m v_0^2 = |q| V \Rightarrow v_0 = \sqrt{\dfrac{2|q| V}{m}}$

★ **ពេលចលនាក្នុងដែនម៉ាញេទិច:** $R = \dfrac{m v_0}{|q| B} = \sqrt{\dfrac{2mV}{|q| B^2}}$ ដែល $V(V)$ : តង់ស្យុង ឬផលសងប៉ូតង់ស្យែល ។



## ★★★មេរៀនទី៧ អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

**I. បាតុភូតអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច:** ជាបាតុភូតកើតឡើងនៅពេលដែលមានបម្រែបម្រួលដែនម៉ាញេទិច ឬបម្រែបម្រួលភ្លុចម៉ាញេទិចកើតមានក្នុងបូប៊ីន ។ ពេលនោះបូប៊ីនដើរតួនាទីជាជនិតាដែលមាន **កម្លាំងអគ្គិសនីចលករអាំងឌុី។**

**II. ភ្លុចម៉ាញេទិច ឬភ្លុចអាំងឌុចស្យុង:** ជាទំហំសម្រាប់សម្គាល់ចំនួនខ្សែដែនម៉ាញេទិចដែលឆ្លងកាត់ផ្ទៃមួយ ។

| | | |
|---|---|---|
| 1). រូបមន្តភ្លុចម៉ាញេទិច: | $\Phi = BA\cos\theta$ | ដែល $\theta = (\vec{B};\vec{n})$ |
| 2). ករណីបូប៊ីនមានចំនួន $N$ ស្ពៀ: | $\Phi = NBA\cos\theta$ | |
| ★បើ $(\vec{B} \perp A)$ នោះ $(\vec{B} \uparrow\uparrow \vec{n})$: | $\Phi = NBA$ | |
| ★បើ $(\vec{B} \uparrow\uparrow A)$ នោះ $(\vec{B} \perp \vec{n})$: | $\Phi = 0$ | |
| ★បើ $(\vec{B};A) = \alpha$ នោះ $\theta = 90° - \alpha$ | | |
| - ផ្ទៃស៊ុមរាងជាការេ: | $A = a^2$ | ($a$: ជ្រុង) |
| - ផ្ទៃស៊ុមរាងជាចតុកោណកែង: | $A = a \times b$ | ($a$: ទទឹង; $b$: បណ្ដោយ) |
| - ផ្ទៃស៊ុមរាងជារង្វង់: | $A = \pi\dfrac{D^2}{4} = \pi r^2$ | ($r$: កាំ; $D$: អង្កត់ផ្ចិត) |
| 3). កម្លាំងអគ្គិសនីចលករអាំងឌុី(ស៊ុមវិលា): | $\lvert E\rvert = N\dfrac{\lvert\Delta\Phi\rvert}{\Delta t} = N\dfrac{\lvert\Phi_2 - \Phi_1\rvert}{\Delta t}$ | |
| 4). កម្លាំងអគ្គិសនីចលករអាំងឌុី(ច្បាប់អូម): | $\lvert E\rvert = V = RI$ | |
| 5). កម្លាំងអគ្គិសនីចលករអាំងឌុី(របារផ្លាស់ទី): | $\lvert E\rvert = Bv\ell\sin\alpha$ | |
| 6). ផ្ទៃកៀសដោយរបារ: | $A = \ell\Delta x = \ell v\Delta t$ | |
| 7). បរិមាណអគ្គិសនីអាំងឌុី: | $Q = I\cdot\Delta t = N\dfrac{\lvert\Delta\Phi\rvert}{R}$ | |
| 8). កម្លាំងអគ្គិសនីចលករអាំងឌុីអតិបរមា: | $E_m = NBA\omega$ | |
| 9). កម្លាំងអគ្គិសនីចលករអាំងឌុីខណៈ: | $e = E_m\sin\omega t = E_m\sin\dfrac{2\pi}{T}t$ | |
| 10). មុំកៀសបាន: | $\theta = \omega t$ | |

- $\Phi$($Wb$ វេប៊ែរ): ភ្លុចម៉ាញេទិច
- $B(T)$: ដែនម៉ាញេទិច ឬអាំងឌុចស្យុង
- $A(m^2)$: ផ្ទៃមុខកាត់ស៊ុម
- $N$ (ស្ពៀ): ចំនួនស្ពៀ
- $\vec{n}$: ខ្សែកែងនឹងផ្ទៃ $A$
- $\theta = (\vec{B};\vec{n})$: មុំផ្គុំរវាងខ្សែកែង $\vec{n}$ និង $\vec{B}$
- $\Delta\Phi = \Phi_2 - \Phi_1$: បម្រែបម្រួលភ្លុចម៉ាញេទិច
- $\Delta t = t_2 - t_1$: បម្រែបម្រួលរយៈពេល ($s$)
- $Q(C)$: បរិមាណអគ្គិសនីអាំងឌុី
- $I(A)$: អាំងតង់ស៊ីតេចរន្ត
- $V(V)$: តង់ស្យុង
- $E(V)$: កម្លាំងអគ្គិសនីចលករអាំងឌុី
- $E_m(V)$: កម្លាំងអ.និចលករអាំងឌុីអតិបរមា
- $e(V)$: កម្លាំងអ.និចលករអាំងឌុីខណៈ
- $R(\Omega)$: រេស៊ីស្តង់សរុប
- $\ell(m)$: ប្រវែងរបាខ្សែចម្លង
- $v(m/s)$: ល្បឿនរបាខ្សែចម្លងផ្លាស់ទី
- $\alpha = (\vec{B};\vec{v})$: មុំផ្គុំរវាង $\vec{B}$ និង $\vec{v}$
- $f$($Hz$; ជុំ/s): ប្រេកង់

★ **វិធានម្រាមដៃស្តាំ:** ដើម្បីកំណត់ទិសដៅនៃចរន្តអាំងឌុីដែលកើតមាននៅក្នុងរបារខ្សែចម្លង គេត្រូវដាក់បាតដៃស្តាំយ៉ាងណាឱ្យវ៉ិចទ័រ $\vec{B}$ ទំលុះបាតដៃ ហើយមេដៃកន្ទែកតាមទិសនៃវ៉ិចទ័រ $\vec{v}$ នោះម្រាមដៃទាំងបួនចង្អុលទិសដៅនៃចរន្តអាំងឌុី $i$ ។

- **ច្បាប់ឡិនទី១:** ចរន្តអាំងឌុីមានទិសដៅយ៉ាងណាឱ្យផលរបស់វាប្រឆាំងនឹងបុព្វហេតុអ្នកឲ្យកំណើតវា ។
- **ច្បាប់ឡិនទី២:** ចរន្តអាំងឌុីបង្កើតដែនម៉ាញេទិចថ្មីមួយដើម្បីប្រឆាំងនឹងបម្រែបម្រួលភ្លុចម៉ាញេទិចដែលឆ្លងកាត់វា ។
- **ចរន្តភូកូលឬចរន្តអេឌី:** គឺជាចរន្តកើតឡើងក្នុងលោហៈពេលមានភ្លុចម៉ាញេទិចឆ្លងកាត់ដុំលោហៈប្រែប្រួល ។
- **ជនិតាអគ្គិសនី:** ជាឧបករណ៍មួយដែលបំលែងពីថាមពលមេកានិចទៅជាថាមពលអគ្គិសនី ។

★ **ម៉ូទ័រអគ្គិសនី:**

- ម៉ូទ័រអគ្គិសនី បំលែងពី: ថាមពលអគ្គិសនី→ថាមពលមេកានិច+ថាមពលកម្តៅ
- ជនិតា បំលែងពី: ថាមពលមេកានិច → ថាមពលអគ្គិសនី+ថាមពលកម្តៅ

ដូច្នេះគេអាចនិយាយថាម៉ូទ័រ និងជនិតាមានភាពរេវ៉ែស៊ីប (ទៅមក) (reversible) ។



## ***មេរៀនទី៨ អូតូអាំងឌុចស្យុង

**I. បាតុភូតអូតូអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច:** ជាបាតុភូតដែលកើតឡើងនៅពេលដែលមានចរន្តប្រែប្រួលឆ្លងកាត់បូប៊ីន។

**1). អាំងឌុចតង់:** ជាមេគុណសមាមាត្ររវាងភ្លុចម៉ាញេទិច $\Phi$ និងចរន្ត $i$ (ប្រែប្រួល) ។

**មានរូបមន្ត:** $\Phi = Li \Rightarrow L = \dfrac{\Phi}{i}$

**2). អាំងឌុចតង់នៃសូលេណូអ៊ីតគ្មានស្នូលដែក:** $L = \dfrac{\mu_0 N^2 A}{\ell}$

**3). អាំងឌុចតង់នៃសូលេណូអ៊ីតមានស្នូលដែក:** $L = \dfrac{\mu_0 \mu_r N^2 A}{\ell}$

**4). កម្លាំងអគ្គិសនីចលករអូតូអាំងឌុី:** $e = -\dfrac{d\Phi}{dt} = -L\dfrac{di}{dt}$

**5). ថាមពលម៉ាញេទិចនៃបូប៊ីន:** $E_L = \dfrac{1}{2}Li^2$

**6). តង់ស្យុងរវាងគោលនៃបូប៊ីន:** $V_{AB} = Ri + L\dfrac{di}{dt}$

**7). ថេរពេលនៃសៀគ្វី $RL$:** $\tau = \dfrac{L}{R}$

**8). អាំងតង់ស៊ីតេចរន្តក្នុងរបបអចិន្ត្រៃយ៍:** $I_P = \dfrac{E}{R}$

**9). អាំងតង់ស៊ីតេចរន្តខណៈ $i$ (ពេលបិទកុងតាក់):** $i = I_P\left(1 - e^{-t/\tau}\right)$ $(e = 2.72)$

☛បើ $t = 1\tau \Leftrightarrow i = I_P\left(1 - e^{-1}\right) = 0.63 I_P$ ចរន្តកើនបាន $63\%$ នៃចរន្តអចិន្ត្រៃយ៍។

☛បើ $t = 5\tau \Leftrightarrow i = I_P\left(1 - e^{-5}\right) = 0.99 I_P$ ចរន្តកើនបាន $99\%$ នៃចរន្តអចិន្ត្រៃយ៍ ។

L : អាំងឌុចតង់ $(H)$(ហង់រី)
$\Phi$ :ភ្លុចម៉ាញេទិច $(Wb)$
$i$: ចរន្តរត់ក្នុងបូប៊ីន $(A)$
$A$ :ផ្ទៃមុខកាត់បូប៊ីន $(m^2)$
$\ell$ :ប្រវែងបូប៊ីន $(m)$
$N$ : ចំនួនស្ពៀ
$\mu_r$ :ដំរាបម៉ាញេទិចធៀបនៃ.ណា១
$\mu_0 = 4\pi \times 10^{-7}\, SI$ ដំរាបម៉ាញេទិចឡាយ
$e$ :កម្លាំងអគ្គិសនីចលករអូតូអាំងឌុី $(V)$
$R$ :រេស៊ីស្តង់ $(\Omega)$
$\tau$ (តូ): ថេរពេល $(s)$
$\dfrac{di}{dt}$ :បម្រែបម្រួលចរន្តធៀបពេល $(A/s)$
$I_P$ :ចរន្តក្នុងរបបអចិន្ត្រៃ $(A)$
$V = E$ : ចំពោះជនិតាអ៊ីដេអាល់ $(V)$
$E$ :កម្លាំងអគ្គិសនីចលករជនិតា $(V)$







**10).** កាលណាគេភ្ជាប់កុងតាក់ $K$ ទៅទីតាំង1 នោះកុងដង់សាទ័រចាប់ផ្ដើមផ្ទុកបន្ទុកអគ្គិសនីរាក៏មានថាមពលអគ្គិសនីបម្រុងទុកក្នុងកុងដង់សាទ័រ: $E_C = \dfrac{1}{2}CV^2 = \dfrac{1}{2}\dfrac{q^2}{C} = \dfrac{1}{2}qV$

**11). បន្ទុកអគ្គិសនីដែលផ្ទុកក្នុងកុងដង់សាទ័រ:** $q = CV$

**12).** កាលណាគេភ្ជាប់កុងតាក់ $K$ ទៅទីតាំង2វិញ កុងដង់សាទ័រផ្ទេរបន្ទុកទៅបូប៊ីនបង្កើតបានជាចរន្តអគ្គិសនីរត់ក្នុងបូប៊ីន។ ហើយបូប៊ីនក៏មានថាមពលម៉ាញេទិចបម្រុងទុក: $E_L = \dfrac{1}{2}Li^2$

**13). ថាមពលសរុបនៃសៀគ្វី $LC$ :** ករណីរេស៊ីស្តង់អាចចោលបាននោះបាតុភូតបណ្ដូរថាមពល ធ្វើឱ្យកើតមានលំយោលអគ្គិសនីជាលំយោលថេរ ។

យើងបាន: $E_{CL} = E_{Cm} = E_{Lm} = \dfrac{1}{2}CV^2 = \dfrac{1}{2}LI_m^2$




**14).** ខួប: $T = 2\pi\sqrt{LC}$ ☛ពុលសាស្យុង: $\omega = \dfrac{1}{\sqrt{LC}}$

**15).** សមីការតង់ស្យុងអគ្គិសនី: $V_C = V_m \cos(\omega t + \varphi_0)$

**16).** សមីការបន្ទុកអគ្គិសនី: $q = q_m \cos(\omega t + \varphi_0)$ ដែល: $q_m = CV_m$

**17).** សមីការចរន្តអគ្គិសនី: $i = I_m \sin(\omega t + \varphi_0)$ ដែល: $I_m = q_m \omega$

$E_C$ :ថាមពលរបស់កុងដង់ $(J)$
$E_L$ :ថាមពលម៉ាញេទិចបូប៊ីន $(J)$
$E_{CL}$ :ថាមពលនៃឌីប៉ូល $LC$
$C$ : កាប៉ាស៊ីតេនៃកុងដង់ $(F)$
$q$ :បន្ទុកនៃកុងដង់ $(C)$ (គូឡុំ)
$V$ :តង់ស្យុង $(V)$
$V_C$ :តង់ស្យុងនៃកុងដង់ $(V)$
$V_L$ :តង់ស្យុងនៃបូប៊ីន $(V)$
$V_m$ :តង់ស្យុងអតិបរមា $(V)$
$I_m$ :ចរន្តអតិបរមា $(A)$
$q_m$ :បន្ទុកអតិបរមា $(C)$
$T$ : ខួបនៃលំយោលអ.នី $(s)$
$f$ : ប្រេកង់ $(Hz)$; ( ជុំ/ទ)
$\omega$: ពុលសាស្យុង $(rad/s)$

## ***មេរៀនទី៩ សៀគ្វីចរន្តឆ្លាស់

**I. ចរន្តឆ្លាស់:** គឺជាចរន្តអគ្គិសនីខួបដែលប្តូរទិសដៅពីរដងក្នុងមួយខួប ។

1). សមីការចរន្តខណៈ: $i = I_m \sin(\omega t + \varphi_i)$ គេបាន: $I_m = I\sqrt{2}$

2). សមីការតង់ស្យុងខណៈ: $v = V_m \sin(\omega t + \varphi_v)$ គេបាន: $V_m = V\sqrt{2}$

**II. ចរន្តឆ្លាស់ឆ្លងកាត់** $R$ : ($v_R$ **ស្របផាសនឹង** $i_R : \varphi_v = 0$)

1). សមីការចរន្តខណៈR : $i_R = I_m \sin(\omega t)$

2). សមីការតង់ស្យុងខណៈR : $v_R = V_{Rm} \sin(\omega t)$

3). តង់ស្យុងប្រសិទ្ធិគោលR : $V_R = RI$

4). តង់ស្យុងអតិបរមាគោលR : $V_{Rm} = RI_m$

5). អាំប៉េដង់រេស៊ីស្តង់R : $Z_R = R$




**III. ចរន្តឆ្លាស់ឆ្លងកាត់** $C$ : ($v_C$ **យឺតផាសជាង** $i_C : \varphi_v = -\frac{\pi}{2}$)

1). សមីការចរន្តខណៈC : $i_C = I_m \sin(\omega t)$

2). សមីការតង់ស្យុងខណៈC : $v_C = V_{Cm} \sin(\omega t - \frac{\pi}{2})$

3). តង់ស្យុងប្រសិទ្ធិគោលC : $V_C = Z_C I$

4). តង់ស្យុងអតិបរមាគោលC : $V_{Cm} = Z_C I_m$

5). អាំប៉េដង់កុងដង់សាទ័រC : $Z_C = \frac{1}{C\omega}$




**IV. ចរន្តឆ្លាស់ឆ្លងកាត់** $L$ : ($v_L$ **លឿនផាសជាង** $i_L : \varphi_v = \frac{\pi}{2}$)

1). សមីការចរន្តខណៈL : $i_L = I_m \sin(\omega t)$

2). សមីការតង់ស្យុងខណៈL : $v_L = V_{Lm} \sin(\omega t + \frac{\pi}{2})$

3). តង់ស្យុងប្រសិទ្ធិគោលL : $V_L = Z_L I$

4). តង់ស្យុងអតិបរមាគោលL : $V_{Lm} = Z_L I_m$

5). អាំប៉េដង់នៃបូប៊ីនL : $Z_L = L\omega$




**V. សៀគ្វី** $RLC$ **តជាស៊េរី:** $I = I_R = I_C = I_L$ & $I_m = I_{Rm} = I_{Cm} = I_{Lm}$

***សំណង់ប្រេណែល: សន្មតថា:** $(V_L > V_C)$

1). សមីការចរន្តខណៈនៃសៀគ្វី : $i = I_m \sin(\omega t)$

2). សមីការតង់ស្យុងខណៈនៃសៀគ្វី : $v = V_m \sin(\omega t + \varphi_v)$

3). តង់ស្យុងប្រសិទ្ធិនៃសៀគ្វី $RLC$ : $V^2 = V_R^2 + (V_L - V_C)^2$

4). តង់ស្យុងអតិបរមានៃសៀគ្វី $RLC$ : $V_m^2 = V_{Rm}^2 + (V_{Lm} - V_{Cm})^2$

5). អាំប៉េដង់សមមូលនៃសៀគ្វី $RLC$ : $Z = \sqrt{R^2 + (Z_L - Z_C)^2}$

6). តង់ស្យុងប្រសិទ្ធនៃសៀគ្វី $RLC$ : $V = ZI$

7). តង់ស្យុងអតិបរមានៃសៀគ្វី $RLC$ : $V_m = ZI_m$







$i(A)$ : ចរន្តខណៈនៃសៀគ្វី
$i_R(A)$ : ចរន្តខណៈនៃរេស៊ីស្តង់
$i_C(A)$ : ចរន្តខណៈនៃកុងដង់សាទ័រ
$i_L(A)$ : ចរន្តខណៈនៃបូប៊ីន
$I(A)$ : ចរន្តប្រសិទ្ធិនៃសៀគ្វី
$I_R(A)$ : ចរន្តប្រសិទ្ធិនៃរេស៊ីស្តង់
$I_C(A)$ : ចរន្តប្រសិទ្ធិនៃកុងដង់សាទ័រ
$I_L(A)$ : ចរន្តប្រសិទ្ធិនៃបូប៊ីន
$I_m(A)$ : ចរន្តអតិបរមានៃសៀគ្វី
$I_{Rm}(A)$ : ចរន្តអតិបរមានៃរេស៊ីស្តង់
$I_{Cm}(A)$ : ចរន្តអតិបរមានៃកុងដង់សាទ័រ
$I_{Lm}(A)$ : ចរន្តអតិបរមានៃបូប៊ីន
$v(V)$ : តង់ស្យុងខណៈគោលសៀគ្វី
$v_R(V)$ : តង់ស្យុងខណៈគោលរេស៊ីស្តង់
$v_C(V)$ : តង់ស្យុងខណៈគោលកុងដង់សាទ័រ
$v_L(V)$ : តង់ស្យុងខណៈគោលបូប៊ីន
$V(V)$ : តង់ស្យុងប្រសិទ្ធិគោលសៀគ្វី
$V_R(V)$ : តង់ស្យុងប្រសិទ្ធិគោលរេស៊ីស្តង់
$V_C(V)$ : តង់ស្យុងប្រសិទ្ធិគោលកុងដង់
$V_L(V)$ : តង់ស្យុងប្រសិទ្ធិគោលបូប៊ីន
$V_m(V)$ : តង់ស្យុងអតិបរមាគោលសៀគ្វី
$V_{Rm}(V)$ : តង់ស្យុងអតិបរមាគោលរេស៊ីស្តង់
$V_{Cm}(V)$ : តង់ស្យុងអតិបរមាគោលកុងដង់
$V_{Lm}(V)$ : តង់ស្យុងអតិបរមាគោលបូប៊ីន
$Z(\Omega)$ : អាំប៉េដង់សមមូលនៃសៀគ្វី
$Z_R = R(\Omega)$ : រេស៊ីស្តង់
$Z_C(\Omega)$ : អាំប៉េដង់របស់កុងដង់សាទ័រ
$Z_L(\Omega)$ : អាំប៉េដង់របស់បូប៊ីន
$C(F)$ : កាប៉ាស៊ីតេរបស់កុងដង់សាទ័រ
$L(H)$ : អាំងឌុចតង់របស់បូប៊ីន
$\varphi_i(rd)$ : ផាសចរន្ត
$\varphi_v(rd)$ : ផាសតង់ស្យុង

8). គម្លាតផាសរវាងចរន្ត និងតង់ស្យុង : $\tan\varphi_v = \frac{V_L - V_C}{V_R} = \frac{Z_L - Z_C}{R}$

9). គម្លាតផាសរវាងចរន្ត និងតង់ស្យុង : $\cos\varphi = \frac{R}{Z}$

❶ $Z_L > Z_C \Rightarrow \tan\varphi_v > 0$: តង់ស្យុងលឿនផាសជាងចរន្ត

❷ $Z_L < Z_C \Rightarrow \tan\varphi_v < 0$: តង់ស្យុងយឺតផាសជាងចរន្ត

❸ $Z_L = Z_C \Rightarrow Z = R$: តង់ស្យុងស្របផាសនឹងចរន្ត ឬ កើតមានបាតុភូតរេសូណង់

## VI. សៀគ្វី $RLC$ តជាខ្នែង: $V = V_R = V_C = V_L$ & $V_m = V_{Rm} = V_{Cm} = V_{Lm}$

★សំណង់ប្រេណែលៈ សន្មតថាៈ $(I_C > I_L)$




1). សមីការតង់ស្យុងខណៈនៃសៀគ្វី : $v = V_m \sin(\omega t)$

2). សមីការចរន្តខណៈនៃសៀគ្វី : $i = I_m \sin(\omega t + \varphi_i)$

3). ចរន្តប្រសិទ្ធនៃសៀគ្វី $RLC$ : $I^2 = I_R^2 + (I_C - I_L)^2$

4). ចរន្តអតិបរមានៃសៀគ្វី $RLC$ : $I_m^2 = I_{Rm}^2 + (I_{Cm} - I_{Lm})^2$

5). អាំប៉េដង់សមមូលនៃសៀគ្វី $RLC$ : $Z = \frac{1}{\sqrt{\frac{1}{R^2} + \left(\frac{1}{Z_C} - \frac{1}{Z_L}\right)^2}}$




6). គម្លាតផាសរវាងចរន្ត និងតង់ស្យុង : $\tan\varphi_i = \frac{I_c - I_L}{I_R} = \left(\frac{1}{Z_C} - \frac{1}{Z_L}\right)R$

7). គម្លាតផាសរវាងចរន្ត និងតង់ស្យុង : $\cos\varphi = \frac{Z}{R}$

## VII. រេសូណង់អគ្គិសនីៈ ជាបាតុភូតដែលទទួលបានចរន្តធំបំផុត(អតិបរមា)ក្នុងសៀគ្វី ។

★លុះត្រាតែៈ $Z_L = Z_C \Leftrightarrow L\omega = \frac{1}{C\omega}$ ★អាំប៉េដង់សមមូលៈ $Z = R$

1). ពុលសាស្យុងៈ $\omega = \frac{1}{\sqrt{LC}}$

2). ប្រេកង់រេសូណង់ៈ $f = \frac{1}{2\pi\sqrt{LC}}$

3). ខួបរេសូណង់ៈ $T = 2\pi\sqrt{LC}$

## VIII. អានុភាពមធ្យម និងកត្តាអានុភាព

1). រូបមន្តអានុភាពៈ $P = VI\cos\varphi = RI^2$ 2). កត្តាអានុភាពៈ $\cos\varphi = \frac{R}{Z}$

## IX. ត្រង់ស្វូម៉ាទ័រ ឬត្រង់ស្វូ

★ត្រង់ស្វូជាឧបករណ៍ប្រើសម្រាប់ដំឡើង ឬបន្ថយតង់ស្យុងឆ្លាស់។






1). ផលធៀបបំលែងត្រង់ស្វូ : $\frac{V_2}{V_1} = \frac{n_2}{n_1}$ (ទិន្នផលពី80% ទៅ99%)

2). ផលធៀបបំលែងត្រង់ស្វូអ៊ីដេអាល់ៈ $\frac{V_2}{V_1} = \frac{n_2}{n_1} = \frac{I_1}{I_2}$ (ទិន្នផល100% ត្រង់ស្វូសុទ្ធ)

$P(W)$: អានុភាពមធ្យម
$\cos\varphi(rad)$: កត្តាអានុភាព
$VI(V\cdot A)$: អានុភាពទំនង
$\frac{V_2}{V_1} = \frac{n_2}{n_1}$ ជាផលធៀបបំលែង
$V_1(V)$: តង់ស្យុងនៅរបុំបឋម
$V_2(V)$: តង់ស្យុងនៅរបុំមធ្យម
$n_1$: ចំនួនស្ពៀនៅរបុំបឋម
$n_2$: ចំនួនស្ពៀនៅរបុំមធ្យម
$I_1(A)$: ចរន្តអ.នីនៅរបុំបឋម
$I_2(A)$: ចរន្តអ.នីនៅរបុំមធ្យម
$P_{e1}(W)$: អានុភាពនៅរបុំបឋម
$P_{e2}(W)$: អានុភាពនៅរបុំមធ្យម
$P_J(W)$: អានុភាពកម្តៅ
$Q_J(J)$: កំហាតថាមពលត្រង់ស្វូ
$t(s)$: រយៈពេលនៃដំណើរការ
$Rd(\%)$: ទិន្នផលត្រង់ស្វូ
$K = \cos\varphi(rad)$: កត្តាអានុភាព

ជូ ចំណាន
Tel: 012 881 986

★ បើ $\frac{V_2}{V_1}=\frac{n_2}{n_1}>1$: ត្រង់ស្វូនេះប្រដាប់ដំឡើងតង់ស្យុង ហៅថា ស្ទុកវ៉ុលទ័រ ។

★ បើ $\frac{V_2}{V_1}=\frac{n_2}{n_1}<1$: ត្រង់ស្វូនេះប្រដាប់បន្ថយតង់ស្យុង ហៅថា ស៊ូវ៉ុលទ័រ ។

**3).** តុល្យភាពអានុភាពត្រង់ស្វូ : $P_{e1}=P_{e2}+P_J$

**4).** អានុភាពនៅរបុំបឋម : $P_{e1}=V_1I_1\cos\varphi$

**5).** អានុភាពនៅរបុំមធ្យម : $P_{e2}=V_2I_2\cos\varphi$

**6).** ទិន្នផលត្រង់ស្វូម៉ាទ័រ : $Rd=\frac{P_{e2}}{P_{e1}}=\frac{V_2I_2}{V_1I_1}$

**7).** កំហាតថាមពលក្នុងត្រង់ស្វូ : $Q_J=P_Jt=RI^2t$

### ★★★ ស្វ័យគុណ

1. $a^n+a^n=2a^n$
2. $a^n\times a^m=a^{n+m}$
3. $(a^n)^m=a^{n\times m}$
4. $(a\times b)^n=a^n\times b^n$
5. $\left(\frac{a}{b}\right)^n=\frac{a^n}{b^n}$
6. $\frac{a^n}{a^m}=a^{n-m}$
7. $a^0=1$
8. $\sqrt[n]{a^m}=a^{\frac{m}{n}}$

### ★★★ បុព្វបទគំរូនៃខ្នាត

1. អិចហ្សា (Exa) : $1E=10^{18}$
2. ប៉េតា (Peta) : $1P=10^{15}$
3. តេរ៉ា (Tera) : $1T=10^{12}$
4. ជីហ្គា (Giga) : $1G=10^{9}$
5. មេហ្គា (Mega) : $1M=10^{6}$
6. គីឡូ (kilo) : $1k=10^{3}$
7. ហិចតូ (hecto) : $1h=10^{2}$
8. ដេកា (deka) : $1da=10^{1}$

ខ្នាត

9. ដេស៊ី (deci) : $1d=10^{-1}$
10. សង់ទី (centi) : $1c=10^{-2}$
11. មីលី (mili) : $1m=10^{-3}$
12. មីក្រូ (micro) : $1\mu=10^{-6}$
13. ណាណូ (nano) : $1n=10^{-9}$
14. ពីកូ (pico) : $1p=10^{-12}$
15. ហ្វិមតូ (femto) : $1f=10^{-15}$
16. អាត់តូ (atto) : $1a=10^{-18}$

### I. វិធានតួលេខមានន័យ

1. លេខ 0 ទាំងឡាយណាដែលនៅចន្លោះលេខមិនសូន្យ ជាលេខមានន័យ (ល.ន)។

**Ex:** ក. 101 : មាន 3 ល.ន
ខ. 2002 : មាន 4 ល.ន
គ. 50106 : មាន 5 ល.ន

2. លេខ 0 ទាំងឡាយណាដែលនៅខាងឆ្វេងខ្ទង់លេខមិនសូន្យដំបូង មិនមែនជាលេខមានន័យទេ។

**Ex:** ក. 0.8 : មាន 1 ល.ន
ខ. 0.00069 : មាន 2 ល.ន
គ. 0.00002018 : មាន 4 ល.ន

3. លេខ 0 ទាំងឡាយណាដែលនៅខាងចុងគេបង្អស់នៃចំនួន ជាលេខមានន័យ និងមិនអាចជាលេខមានន័យ ។

**Ex:** ក. 400 : អាចមាន 1 ល.ន ($4\times10^2$)
: អាចមាន 2 ល.ន ($4.0\times10^2$)
: អាចមាន 3 ល.ន ($4.00\times10^2$)

### II. ប្រមាណវិធី បូក ឬដក:
ក្នុងវិធីបូក ឬដក នៃចំនួនគេត្រូវយកលទ្ធផល តាមចំនួនដើមដែលមានខ្ទង់ក្រោយក្បៀសតិចជាងគេ។

**Ex:** ក. 89.332 + 1.1 = 90.432 **លទ្ធផល** =90.4
ខ. 88.19 + 2.168 = 90.258 **លទ្ធផល** =90.27
គ. 2.097 – 0.12 = 1.977 **លទ្ធផល** =1.98

### III. ប្រមាណវិធី គុណ ឬចែក:
ក្នុងការគុណ ឬចែក នៃចំនួនគេត្រូវយកលទ្ធផល តាមចំនួនតួលេខមានន័យតិចជាងគេ។

**Ex:** ក. $8.16\times5.1355=41.90568$
**លទ្ធផល** =41.9

ខ. $0.0154\div88.3=0.0001744$
**លទ្ធផល** $=0.000174=174\times10^{-6}$

គ. $6.85\div112.04=0.0611388$
**លទ្ធផល** $=0.0611=611\times10^{-4}$

ឃ. $\frac{6.67\times10^7\times3.2\times10^{-2}}{8.55\times10^4}=2.49637\times10^1$
**លទ្ធផល** $=2.5\times10^1=25$